# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមហ៊ុន សាន់ ស៊ូ ហ្គាម៉ិន ខូអិលធីឌី**

# កិច្ចព្រមព្រៀង

## ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១ខែ

ថ្ងៃព្រហស្បតិ៍ ៧កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ៨:០០ នាទីព្រឹក មានកិច្ចប្រជុំមួយនៅរោងចក្រ សាន់ ស៊ូ ហ្គាម៉ិន ខូអិលធីឌី មានអាសយដ្ឋានស្ថិតនៅភូមិ កប្បាស ឃុំខ្វិតធំ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដោយមានលោក LIN FANG CHENG ជានាយកក្រុមហ៊ុន បានបើកកិច្ចប្រជុំមួយជាមួយ លោក ធឹម ថា ជាប្រធានសហជីព និង បងប្អូនដែលជាប្រតិភូបុគ្គលិក ចំនួន ៣០ រូបផ្សេងទៀត ដែលតំណាងអោយកម្មករ កម្មការិនីសរុប ៣០១៥ នាក់។

ជាកិច្ចចាប់ផ្តើមលោក LIN FANG CHENG ជាប្រធានអង្គប្រជុំ បានមានមតិស្វាគមន៍ដល់បងប្អូនប្រតិភូមបុគ្គលិក ទាំងអស់ដែលបានចូលរួម និង បានបើកកិច្ចពិភាក្សាអំពីការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតនៅផ្នែកពុម្ព ចំនួន ១០៧ នាក់ សម្រាប់រយៈពេល ១ខែ ដោយគឺចាប់ពីថ្ងៃទី១៣ ខែ មករា ឆ្នាំ២០២៣ ដល់ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយសារស្ថានភាពបញ្ជាទិញរបស់អតិថិជនមានការធ្លាក់ចុះយ៉ាងខ្លាំង។

ក្រោយការពិភាក្សាគ្នា រវាងភាគីតំណាងក្រុមហ៊ុន និង ប្រតិភូបុគ្គលិក រួចមក ភាគីទាំងពីរបានឯកភាពផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតម្នាក់ៗចំនួន ៥០ដុល្លារ រួមទាំង រក្សាប្រាក់រង្វាន់ទៀងទាត់ ១០ដុល្លារ និងប្រាក់ឧបត្ថម្ភថ្លៃធ្វើដំណើរ ស្នាក់នៅ ៧ ដុល្លារ ក្នុងកំឡុងពេលនៃការព្យួរនេះ និង បើកជូនបងប្អូនកម្មករ និយោជិតនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣។

កិច្ចពិភាក្សាបានបញ្ចប់ នៅវេលាម៉ោង ២:៣០ នាទីរសៀល នៅថ្ងៃខែឆ្នាំដដែល ក្រោមស្មាតីយោគយល់គ្នា និង ទទួលយកនូវស្មារតីនៃកិច្ចព្រមព្រៀងនេះ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ព្រៃឈរ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០២២

**ភាគីទាំងពីរបានឯកភាព និង ផ្តិតមេដៃទុកជាភស្តុតាង**

| **ប្រតិភូបុគ្គលិក** | | | **តំណាងក្រុមហ៊ុន** |
|---|---|---|---|
| ធឹម ថា | ជា គឹមឡាត់ | វ៉េង ណារ៉ា | ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន សាន់ ស៊ូ ហ្គាម៉ិន SUN HSU GARMENT Co.,Ltd KINGDOM OF CAMBODIA<br>**លោក** LIN FANG CHENG |

| | | | |
|---|---|---|---|
| ទឹម ម៉េងអ៊ី | ជួន សេងហួរ | ផៃ ស្រីនាង | ដុះ ឃុនស្រីពៅ |
| ម៉ម ប៉ូឡូ | ស៊ិន សុខនៃ | ម៉េស ស្រីមុំ | លី ចាន់ថា |
| ធឹម ធី | ឃើម ណាក់ | ភោគ ថាវី | សាំ ចាន់នី |
| លីម លុច | គូ ចំរើន | ចាន់ ដាលីន | គីម ធីម |
| ជុំ សិលា | ថុល សៅ | ឈុំ លីនណា | ថៃ សុផល |
| ចែម រ៉ា | ជឿន ស្រីល័ក្ខ | មួន ណារ៉េន | យ៉ាន់ ស្មើ |
| ស៊ឹម ស្រីម៉ៅ | ហួ វណ្ណា | សួន សំណាង | ម៉ន ចាន់បូផា |